**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/ ១៥៨ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

www.pheakdeylaw.com

# សម្រេច

**មាត្រាមួយៈ** ត្រូវបានកែសម្រួលមាត្រា ៥ នៃអនុក្រឹត្យលេខ ៨៧ អនក្រ. បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដូចតទៅ ៖

**មាត្រា៥ថ្មី៖** អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នេះមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ស៊ុំ ម៉ានិត** | ទីប្រឹក្សារាជរដ្ឋាភិបាល | ប្រធាន |
| ២- ឯកឧត្តម **អង្គ វង្សវឌ្ឍនា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- ឯកឧត្តម **សំ សុខផល** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៥- ឯកឧត្តម **ទី តាយី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម **ឡើយ មួន** | សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | សមាជិក |
| ៧- ឯកឧត្តម **ហែម គ្រាញ់តូនី** | អនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- ឯកឧត្តម **ម៉ៅ ថូរ៉ា** | អនុរដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- ឯកឧត្តម **ឆាំល់ ចំនួនតារា** | មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ១០-លោក **កើត រិទ្ធិ** | ជំនួយការស្រាវជ្រាវនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |

**មាត្រាពីរ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រាពីរ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com